លេខ: D56/14

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**លេខសំណុំរឿង: ០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស**

| | |
|---|---|
| ចំពោះមុខ ៖ | **សហចៅក្រមស៊ើបអង្កេត** |
| កាលបរិច្ឆេទ ៖ | **ថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៣** |
| ភាសាដើម ៖ | **ខ្មែរ/អង់គ្លេស [ភាសាដើម៖ អង់គ្លេស]** |
| ចំណាត់ថ្នាក់ឯកសារ ៖ | **សម្ងាត់បំផុត ប្តូរទៅជាសាធារណៈ** |

---

# ដីកាសម្រេចបន្តឡើងវិញនូវកាលបរិច្ឆេទសម្រាប់ការដាក់ឯកសារស្តីពីបញ្ហាចោទប្រកាន់អំពីអត្ថិភាពនៃទំនាស់ផលប្រយោជន៍នៅក្នុងការតំណាងផ្លូវច្បាប់របស់មាស មុត

---

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas Henry Koumjian

**ចម្លងជូន**

Isaac ENDELEY
**សហមេធាវីដែលត្រូវបានតែងតាំង**
អាង ឧត្តម
Michael KARNAVAS

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception):
02 / 10 / 2013
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទាក់ទងនឹងសំណុំរឿង ០០៣[១] ដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ [២]។

**បានឃើញ** កិច្ចស៊ើបសួរទាក់ទិននឹងបទចោទប្រកាន់អំពីការរំលោភបំពានលើ**ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** និង**ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** ជាបទល្មើសដែលមានចែង និងត្រូវផ្តន្ទាទោសតាមមាត្រា ៣, ៥, ៦, ២៩ និង ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ៥០០, ៥០១, ៥០៣, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦។

**បានឃើញ** វិធាន ៧២ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ។

**បានឃើញ** មាត្រា ៨ នៃសេចក្តីណែនាំអនុវត្តន៍ស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ។

**បានឃើញ**ថា នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ចៅក្រម យូ ប៊ុនឡេង និងចៅក្រម Harmon ("ស.ច.ស.អ") បានចុះហត្ថលេខាលើកំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ពាក់ព័ន្ធ ដូចជាដីកាសម្រេចនេះ។

---

[១] សំណុំរឿង០០៣ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ។

[២] សំណុំរឿង០០៣ ឯកសារ D1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពី* ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ។

## ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដោយពិចារណាទៅលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីលទ្ធភាពអត្ថិភាពនៃទំនាស់ផលប្រយោជន៍របស់សហមេធាវីដែលត្រូវបានតែងតាំង នៅក្នុងការតំណាងផ្លូវច្បាប់របស់មាស មុត ("ជនសង្ស័យ")[3] ស.ច.ស.អ បានស្នើសហមេធាវីដែលត្រូវបានតែងតាំង ឱ្យដាក់សារណាស្តីពីបញ្ហានេះ ហើយបានស្នើសហព្រះរាជអាជ្ញា ឱ្យឆ្លើយតបទៅនឹងសារណាពីសហមេធាវីដែលត្រូវបានតែងតាំង[4]។

2. នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ នៅក្នុងការឆ្លើយតបទៅនឹងការវិវត្តថ្មីៗបណ្តាលមកពីការស្លាប់របស់ អៀង សារី (អតីតជនជាប់ចោទ នៅក្នុងសំណុំរឿង ០០២) ស.ច.ស.អ បានកំណត់កាលបរិច្ឆេទថ្មីសម្រាប់ការដាក់សេចក្តីសន្និដ្ឋាន និងសារណាពីភាគីទាំងពីរ[5]។

3. នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ ប្រធានអង្គភាពគាំពារការពារក្តី ("អ.គ.ក") បានសម្រេចកំណត់ថា ជនសង្ស័យ មិនមែនជាជនក្រីក្រ ដូច្នេះគ្មានសិទ្ធិទទួលបានជំនួយក្រោមគ្រោងការជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក ឡើយ[6]។

4. នៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣ ស.ច.ស.អ បានពន្យារពេលកាលបរិច្ឆេទថ្មីដែលបានកំណត់នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ ដោយរង់ចាំសេចក្តីសម្រេចរបស់ជនសង្ស័យទាក់ទងនឹងតំណាងផ្លូវច្បាប់របស់គាត់[7]។

---

[3] *សូមមើល* សំណុំរឿង ០០៣ ឯកសារ D56/1 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើឱ្យបដិសេធការការតែងតាំងសហមេធាវីដែលត្រូវបានតែងតាំង ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍មិនអាចផ្សះផ្សាបាន* ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២។

[4] សំណុំរឿង ០០៣ ឯកសារ D56/3 *ដីកាសម្រេច និងដីកាសម្រេចកំណត់កាលបរិច្ឆេទទាក់ទងនឹង សំណើសុំការតែងតាំងសហមេធាវីដែលត្រូវបានតែងតាំង* ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ២៥-៣០។

[5] សំណុំរឿង ០០៣ ឯកសារ D56/5 *ដីកាសម្រេច និងដីកាសម្រេចកំណត់កាលបរិច្ឆេទលើកទីពីរទាក់ទងនឹងសំណើសុំការតែងតាំង សហមេធាវីដែលត្រូវបានតែងតាំង* ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ១៤-១៥។

[6] សំណុំរឿង ០០៣ ឯកសារ D56/11 *ការកំណត់លើការអះអាងនៃភាពក្រីក្ររបស់លោក និងសម្រេចក្តីសម្រេចលើសំណើសុំបើកប្រាក់កម្រៃសហមេធាវីក្រោមគ្រោងការជំនួយផ្នែកច្បាប់ របស់ អ.វ.ត.ក* ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣។

5. នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ជនសង្ស័យ បានដាក់បណ្ដឹងតវ៉ាស្នើ សហចៅក្រមស៊ើបអង្កេត ច្រានចោលការកំណត់អំពីភាពក្រីក្រធ្វើឡើងដោយ អ.គ.ក ហើយនៅថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១៣ ជនសង្ស័យ បានដាក់សារណាបន្ថែមគាំទ្របណ្ដឹងតវ៉ារបស់គាត់ [8]។

6. នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៣ ស.ច.ស.អ បានលុបចោលការកំណត់អំពីភាពក្រីក្រធ្វើឡើងដោយ អ.គ.ក ហើយបង្គាប់ អ.គ.ក ឱ្យវាយតម្លៃឡើងវិញលើបញ្ហាភាពក្រីក្ររបស់ជនសង្ស័យ ដោយពិចារណាលើកត្តាផ្សេងៗដែលត្រូវបានពិចារណានៅក្នុងដីកាសម្រេចលើបណ្ដឹងតវ៉ា [9]។

7. នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣ អ.គ.ក បានចេញ*ការកំណត់ជាចុងក្រោយលើការអះអាងនៃភាពក្រីក្ររបស់លោក និងសេចក្ដីសម្រេចលើសំណើសុំបើកប្រាក់កម្រៃសហមេធាវីក្រោមគ្រោងការជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក* ដោយក្នុងនេះ ប្រធាន អ.គ.ក បានសម្រេចកំណត់ថា ជនសង្ស័យពិតជាជនក្រីក្រ ហើយមានគុណវុឌ្ឍិទទួលបានប្រាក់កម្រៃមេធាវី [10]។

---

[7] សំណុំរឿង ០០៣ ឯកសារ D56/12 *ដីកាសម្រេចលើការប្រាស្រ័យទាក់ទងរវាងសហមេធាវីដែលត្រូវបានតែងតាំងជាមួយនឹងជនសង្ស័យ* ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ១៥-១៦។

[8] សំណុំរឿង ០០៣ ឯកសារ D56/11/2 *បណ្ដឹងតវ៉ារបស់ មាស មុត ប្រឆាំងទៅនឹងការកំណត់លើការអះអាងនៃភាពក្រីក្រ និងសេចក្ដីសម្រេចលើសំណើសុំបើកប្រាក់កម្រៃសម្រាប់សហមេធាវីក្រោមគ្រោងការជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក* ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣។ សំណុំរឿង ០០៣ ឯកសារ D56/11/2.2 *ឧបសម្ព័ន្ធនៃបណ្ដឹងតវ៉ាជំទាស់នឹងការសម្រេចចំពោះការអះអាងពីភាពក្រីក្រ និងសេចក្ដីសម្រេចលើសំណើសុំចំណាយលើថ្លៃមេធាវី* ចុះថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ២០១៣។ សំណុំរឿង ០០៣ ឯកសារ D56/11/4 *សារណាបន្ថែមរបស់មាស មុត ដើម្បីគាំទ្របណ្ដឹងតវ៉ារបស់គាត់ប្រឆាំងទៅនឹងការកំណត់លើការអះអាងនៃភាពក្រីក្រនិងសេចក្ដីសម្រេចលើសំណើសុំបើកប្រាក់កម្រៃសម្រាប់សហមេធាវី ក្រោមគ្រោងការជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក* ចុះថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១៣។

[9] សំណុំរឿង ០០៣ ឯកសារ D56/11/7 *ដីកាសម្រេចលើបណ្ដឹងតវ៉ាប្រឆាំងនឹងការកំណត់របស់អង្គភាពគាំពារការពារក្ដីលើបញ្ហាភាពក្រីក្ររបស់មាស មុត* ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ១០៦-១០៧។

[10] សំណុំរឿង ០០៣ ឯកសារ D56/13 *ការកំណត់ជាចុងក្រោយលើការអះអាងនៃភាពក្រីក្ររបស់លោក និង សេចក្ដីសម្រេចលើសំណើសុំបើកប្រាក់កម្រៃសហមេធាវីក្រោមគ្រោងការជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក* ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១០។

## ដីកាសម្រេច

8. ដោយ អ.គ.ក បានធ្វើសេចក្តីសម្រេចចុងក្រោយលើការកំណត់អំពីភាពក្រីក្ររបស់ជនសង្ស័យនោះ ស.ច.ស.អ ឥឡូវនេះស្ថិតនៅក្នុងតួនាទីមួយត្រូវពិចារណាលើបញ្ហាទំនាស់ផលប្រយោជន៍ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ។ ដូច្នេះ ជាការសមស្របដែលត្រូវបន្តឡើងវិញនូវកាលបរិច្ឆេទសម្រាប់ការដាក់ឯកសារដែលត្រូវបានពន្យារពេលតាម*ដីកាសម្រេចលើការប្រាស្រ័យទាក់ទងរវាងសហមេធាវីដែលត្រូវបានតែងតាំងជាមួយនឹងជនសង្ស័យ*[11]។

**តាមសំអាងហេតុខាងលើ ខ្ញុំ MARK B. HARMON ៖**

9. **លុបចោល** ការពន្យារពេលកាលបរិច្ឆេទសម្រាប់ការដាក់ឯកសារដែលបានបង្គាប់នៅក្នុង*ដីកាសម្រេចលើការប្រាស្រ័យទាក់ទងរវាងសហមេធាវីដែលត្រូវបានតែងតាំង ជាមួយនឹងជនសង្ស័យ*។

10. **ស្នើ** សហព្រះរាជអាជ្ញា ឆ្លើយតបទៅនឹង*ការឆ្លើយតបរបស់សហមេធាវី ទៅនឹងសេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីទំនាស់ផលប្រយោជន៍របស់សហមេធាវីដែលត្រូវបានតែងតាំង* ដោយធ្វើការឆ្លើយតបនេះក្នុងរយៈពេល ប្រាំ (៥) ថ្ងៃនៃថ្ងៃធ្វើការនៅពេលដែលដាក់ដីកាសម្រេចនេះ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៣

**ចៅក្រម Mark B. Harmon**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
International Co-Investigating Judge
Co-juge d'instruction international

[11] សំណុំរឿង ០០៣ ឯកសារ D56/12 *ដីកាសម្រេចលើការប្រាស្រ័យទាក់ទងរវាងសហមេធាវីដែលត្រូវបានតែងតាំងជាមួយនឹងជនសង្ស័យ* ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ១៦។